គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org
ខុមហ្វ្រែល/COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1. លោក ធុន សារាយ
Mr. THUN Saray
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2. លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

3. លោក យឹម ប៉ូ
Mr. YIM Po អគ្គលេខាធិការ
និងជានាយក CCPCR

4. អ្នកស្រី ស៊ុន ចាន់សែន
Mrs. SUN Chansen សមាជិកា
និងជាប្រធាន KYA

5. លោក យ៉ង់ គិមអេង
Mr. YONG Kim Eng សមាជិក
និងជានាយក PDP-Center

6. លោក មុំ សារិន
Mr. MOM Sarin សមាជិកា
និងជានាយក HRCDO

7. អ្នកស្រី ទីវ សារាយេត
Ms. TIV Sarayet សមាជិកា
និងជាសហនាយិកា WMC

8. កញ្ញា សយ សារា វឌ្ឍនី
Miss. SAY Sara Vathany
សមាជិកា
និងជានាយិកា CWCC

9. លោក គីម សុវណ្ណ
Mr. KIM Sovann សមាជិក
និងជានាយក VIGILANCE

10. នាយក LAC (NA)

11. នាយក KKKHRO (NA)

12. អ្នកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep សមាជិកា
ជាឥស្សរជន Dignitary

13. លោក សិន សែត
Mr. SEN Set សមាជិក
ជាឥស្សរជន Dignitary

ស.ប្រ.ក.៣/លេខ ០៦/១០ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត ប៉ៃលិន

*ភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តប៉ៃលិនប្រមាណ ១00នាក់ ក្នុងនោះមាន ស្ត្រី ៣៥នាក់ (៣៥%) មកពីសហគមន៍ព្រៃឈើ ដីធ្លី,,,,,,, អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ដែលមកពីស្រុកសាលាក្រៅ និងក្រុងប៉ៃលិនក្នុងខេត្តប៉ៃលិនបានបង្ហាញពីការពេញចិត្តច្រើនទៅលើការបំពេញការងារមន្ត្រីជាប់ឆ្នោត ក្នុងការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តប៉ៃលិន បើទោះបីជាចំនុចនៃលក្ខខណ្ឌសន្ទស្សន៍ខ្លះមិនទាន់ត្រូវបានអនុវត្ត ឬអនុវត្តបានតិចតួចក៏ដោយ។

ភាគច្រើននៃលក្ខខណ្ឌសន្ទស្សន៍ត្រូវបានម្ចាស់ឆ្នោតភាគច្រើនវាយតម្លៃ នៅចន្លោះមិនបានធ្វើទាល់តែសោះទៅបានធ្វើខ្លះៗ ដូចជាការសុំកសាងប្រឡាយទឹកនៅឃុំស្ទឹងត្រង់ ការសុំតម្លើងប្រាក់បៀវត្សន៍ចាប់ពីមេភូមិ មេឃុំ និងសំរាប់មន្ត្រីរាជការនៅខេត្តប៉ៃលិន ជាដើម។

មានលក្ខខណ្ឌសន្ទស្សន៍តែ ៣ ប៉ុណ្ណោះដែលត្រូវបានម្ចាស់ឆ្នោតភាគច្រើនវាយតម្លៃថា ត្រូវបានអនុវត្ត ឬបំពេញ បានពាក់កណ្តាល ឬបានច្រើន ដូចជាការរកទីផ្សារសេរីលក់ផលិតផលកសិកម្ម ការសុំផ្លូវ និងស្ពាន និងការបើកប្រាក់បៀវត្សរ៍គ្រូបង្រៀនអោយបានទៀងទាត់។

ឯកឧត្តម **កើត សុធា** និង លោកជំទាវ **វ៉ែន ដារ៉ា** សមាជិកក្រុមប្រឹក្សាខេត្ត លោក **មៀវ សាម៉ៃ** នាយរងខុទ្ទកាល័យសាលាខេត្ត បានមានប្រសាសន៍ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ដែលការអនុវត្តលក្ខខណ្ឌសន្ទស្សន៍នេះជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា ក៏ដូចជាអាជ្ញាធរខេត្ត ជាពិសេសមន្ត្រីជាប់ឆ្នោត។ ហើយរាល់បញ្ហាដែលបានលើកឡើងក្នុងវេទិកានឹងត្រូវយកចិត្តទុកដាក់ និងធ្វើការពិភាក្សាដើម្បីអោយខេត្តប៉ៃលិនមានការរីកចំរើនទៅមុខ។

ការវាយតម្លៃនេះ ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចនីមួយៗដែលម្ចាស់ឆ្នោតបានធ្វើការទាមទារកាលពី ខែកក្កដា ឆ្នាំ២០០៩ ដោយឱ្យពិន្ទុ "ពិន្ទុ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច(ច្រើនបំផុតត្រឹម ២០%)" "ពិន្ទុ២ សំរាប់ការបានធ្វើខ្លះ (២១%-៤០%)"

"ពិន្ទុ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ៥ សំរាប់ ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)"។

ជាលទ្ធផល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២០០៩ ដូចខាងក្រោមៈ

| **លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអធិភាពទាំងដប់នៅក្នុងខេត្តប៉ៃលិន** |
|---|
| ១) សុំរកទីផ្សារសេរីសំរាប់លក់ផលិតផលកសិកម្មដូចជា ស្រូវ ដំឡូងមី សណ្តែកបាយ ពោត,,,,យ៉ាងហោចណាស់មួយគីឡូក្រាមជាមធ្យម អោយបាន ២៥% នៃតម្លៃសាំង ១ លីត្រ នៅខេត្តប៉ៃលិន ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០០៩ នេះតទៅ ។<br>ពិន្ទុ **១ (៤%)** ពិន្ទុ **២ (១៤%)** ពិន្ទុ **៣ (៥១%)** ពិន្ទុ **៤ (២៨%)** ពិន្ទុ **៥(២%)** |
| ២) សុំអោយមានការនាំចេញ ចូល កសិផល និងយកពន្ធតិចជាងតម្លៃបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩] ប្រហែល ៥០% នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ ២០០៩។<br>ពិន្ទុ **១ (៦%)** ពិន្ទុ **២ (៦១%)** ពិន្ទុ **៣ (២៤%)** ពិន្ទុ **៤ (៥%)** ពិន្ទុ **៥(៥%)** |
| ៣) ត្រូវអោយមានការត្រួតពិនិត្យ និងបណ្តុះបណ្តាលតាមបច្ចេកទេសដោយមន្ទីរកសិកម្មខេត្ត ។ ពូជដំណាំកសិកម្មដែលនាំចូលអោយមាន តម្លៃទាបជាងតម្លៃបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩] ដល់កសិករក្នុងខេត្តប៉ៃលិនចាប់ពីឆ្នាំ ២០១០ នេះតទៅ ។<br>ពិន្ទុ **១ (១៣%)** ពិន្ទុ **២ (៥៣%)** ពិន្ទុ **៣ (២៤%)** ពិន្ទុ **៤ (៨%)** ពិន្ទុ **៥(២%)** |
| ៤) សុំអោយមានប្រឡាយទឹកនៅឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅដែលប្រឡាយមានប្រវែង ៣០គម ទំហំ មាត់លើ ៥ ម៉ែត្រ ពិចំនុចភូមិទំនប់ ដល់ទីប្រជុំជនឃុំស្ទឹងត្រង់ចាប់ពីឆ្នាំ ២០១០ ដល់ ២០១២ ។<br>ពិន្ទុ **១ (៤១%)** ពិន្ទុ **២ (៤១%)** ពិន្ទុ **៣ (១៤%)** ពិន្ទុ **៤ (១%)** ពិន្ទុ **៥(២%)** |
| ៥) សុំផ្លូវគ្រួសក្រហម និងស្ពានចំនួន 0៤ ខ្សែ ចាប់ពីឆ្នាំ ២០១០ ដល់ ២០១៥។ ទី ១ នៅក្នុងសង្កាត់អូរតាវៅ ពីភូមិប៉ាងរលឹម ដល់ភូមិក្រចាប់លើ ប្រហែល ១២ គម ។ ទី ២ ក្នុងឃុំអូរអណ្តូងចាប់ពី ភូមិថ្មល់កែង ដល់ភូមិកូនដំរី ឃុំស្ទឹងត្រង់ មានប្រវែងប្រហែល ១៨គម ។ ទី ៣ ពីភូមិភ្នំកុយ ដល់ភូមិស្រែអន្ទាក់ ក្នុងឃុំសាលាក្រៅ ប្រវែង ៨គម ។ និងទី ៤ សុំស្ពានមួយកន្លែងនៅភូមិបតាំងស៊ូ សង្កាត់បយ៉ាខា ។<br>ពិន្ទុ **១ (៩%)** ពិន្ទុ **២ (២៦%)** ពិន្ទុ **៣ (៣៣%)** ពិន្ទុ **៤ (២៧%)** ពិន្ទុ **៥(៤%)** |
| ៦) សុំតម្លើងប្រាក់ឧបត្ថម្ភចាប់ពីមេភូមិ មេឃុំ អោយបាន ១០០% នៃប្រាក់ឧបត្ថម្ភបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩]។ សំរាប់មន្ត្រីរាជការគ្រប់ស្ថាប័នក្នុងខេត្តប៉ៃលិន សុំតម្លើងប្រាក់ខែប្រចាំខែអោយបាន ៤០% ជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០១០ តទៅ ។<br>ពិន្ទុ **១ (៥១%)** ពិន្ទុ **២ (៣៩%)** ពិន្ទុ **៣ (៤%)** ពិន្ទុ **៤ (៤%)** ពិន្ទុ **៥(១%)** |
| ៧) សុំអោយមានឥណទានដែលមានការប្រាក់ទាប (១%ក្នុង១ខែ) សំរាប់ប្រជាពលរដ្ឋដែលជាកសិករខ្វះនៅក្នុង ខេត្តប៉ៃលិន ពីឆ្នាំ ២០១០ ដល់ ២០១៥ ។<br>ពិន្ទុ **១ (៣៩%)** ពិន្ទុ **២ (៤៥%)** ពិន្ទុ **៣ (១៤%)** ពិន្ទុ **៤ (១%)** ពិន្ទុ **៥(១%)** |

៨) សុំអោយមានការព្យាបាលជំងឺដោយពុំយកកំរៃសេវាព្យាបាលក្នុងមន្ទីរពេទ្យបង្អែក ក្នុងខេត្តប៉ៃលិនឬបញ្ចុះតំលៃ ៥0%ពីតម្លៃបច្ចុប្បន្ន [ខែកក្កដា ឆ្នាំ ២០០៩] អោយបាននៅក្នុងឆ្នាំ ២០១០ ។

ពិន្ទុ **១ (១២%)** ពិន្ទុ **២ (៤0%)** ពិន្ទុ **៣ (៣៨%)** ពិន្ទុ **៤ (៩%)** ពិន្ទុ **៥(១%)**

៩) សុំអោយបង្កើតច្បាប់ប្រឆាំងអំពើពុករលួយអោយបាននៅចុងឆ្នាំ ២០០៩ ខាងមុខនេះតទៅ ។

ពិន្ទុ **១ (៥%)** ពិន្ទុ **២ (២៣%)** ពិន្ទុ **៣ (៣៩%)** ពិន្ទុ **៤ (២១%)** ពិន្ទុ **៥(១៣%)**

១០) សុំតម្លើងប្រាក់បៀវត្សរ៏គ្រូបង្រៀនយ៉ាងតិច ៤0ម៉ឺនរៀលក្នុងមួយខែ បើកអោយបានទៀងទាត់រៀងរាល់ខែ នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ ២០១០ ។

ពិន្ទុ **១ (៣%)** ពិន្ទុ **២ (៧%)** ពិន្ទុ **៣ (៤១%)** ពិន្ទុ **៤ (៣៦%)** ពិន្ទុ **៥(១៣%)**

១១) **ចំនុចរួមៈ តើអ្នកពេញចិត្តការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំង10 កម្រិតណា?**

□ ១) មិនពេញចិត្តទាល់តែសោះ, □២) ពេញចិត្តតិចតួច, □ ៣) ពេញចិត្តគួរសម, □៤) ពេញចិត្តច្រើន, □៥) ពេញចិត្តទាំងស្រុង

ពិន្ទុ **(៤%)** ពិន្ទុ **(៦%)** ពិន្ទុ **(២៧%)** ពិន្ទុ **(៤៨%)** ពិន្ទុ **(១៥%)**

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតនៅខេត្តប៉ៃលិននៅថ្ងៃទី ២៤ មិថុនា ដែលរៀបចំដោយគណៈកម្មាធិការ**ខុមហ្វ្រែល** ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) និង អង្គការឃែរកម្ពុជា ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទងៈ*

- លោក **សុខ ពិនូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទៈ ០៨៩ ៥២៥ ៤៤៦